# មហាអនុតំបន់ទន្លេមេគង្គ
# កិច្ចព្រមព្រៀងសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន (CBTA)

# ព្រះរាជាណាចក្រកម្ពុជា
## គោលការណ៍ណែនាំស្តីពីការអនុវត្ត CBTA
## «ដំណាក់កាលប្រមូលផលជំហានដំបូង (EARLY HARVEST)»

### តើអ្វីទៅជាកិច្ចព្រមព្រៀងសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន (CBTA) នៃមហាអនុតំបន់ទន្លេមេគង្គ?

- ប្រទេសជាសមាជិកទាំង ៦ នៃមហាអនុតំបន់ទន្លេមេគង្គ (រួមមាន កម្ពុជា ចិន ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម) បានផ្តល់សច្ចាប័នលើ CBTA នៅក្នុងឆ្នាំ ២០១៥ ប៉ុន្តែនៅមានផ្នែកមួយចំនួននៃ CBTA ពុំទាន់សម័យកាល ដែលត្រូវធ្វើការកែសម្រួល។
- នៅក្នុងឆ្នាំ២០១៦ រដ្ឋមន្ត្រីដឹកជញ្ជូននៃមហាអនុតំបន់ទន្លេមេគង្គ ដែលជាសមាជិកនៃ «គណៈកម្មាធិការរួម» ទទួលបន្ទុកចាត់ចែង CBTA បានព្រមព្រៀងចាប់អនុវត្ត CBTA «ដំណាក់កាលប្រមូលផលជំហានដំបូង (Early Harvest)» ជាវិធានបណ្តោះអាសន្នសម្រាប់ឆ្នាំ២០១៨ មុនពេលដែលកិច្ចព្រមព្រៀងនេះ ត្រូវបានធ្វើបច្ចុប្បន្នភាព។
- បើទោះបីជា លិខិតអនុញ្ញាត (Permits) ជាច្រើនត្រូវបានផ្តល់ជូន ប៉ុន្តែការបិទទ្វារច្រកព្រំដែននៅក្នុងឆ្នាំ២០២០ ធ្វើឱ្យការអនុវត្ត «ដំណាក់កាលប្រមូលផលជំហានដំបូង (Early Harvest)» ត្រូវបានពន្យារពេល។
- នៅក្នុងខែធ្នូ ឆ្នាំ២០២៣ រដ្ឋមន្ត្រីដឹកជញ្ជូននៃប្រទេសមហាអនុតំបន់ទន្លេមេគង្គ បានសម្រេចចាប់ផ្តើមអនុវត្តឡើងវិញនូវ «ដំណាក់កាលប្រមូលផលជំហានដំបូង (Early Harvest)» មានសុពលភាពចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៦ ជារយៈពេលអនុវត្តលើកដំបូង។
- តំណភ្ជាប់ https://www.adb.org/sites/default/files/publication/29294/gms-cbta-instruments-history.pdf មានភ្ជាប់ជូននូវអត្ថបទទាំងស្រុងស្តីពី CBTA។

### តើអ្វីទៅជា CBTA «ដំណាក់កាលប្រមូលផលជំហានដំបូង (Early Harvest)»?

- «ដំណាក់កាលប្រមូលផលជំហានដំបូង (Early Harvest)» គឺអនុលោមទៅតាមអនុស្សរណៈយោគយល់ (MoU) មួយ ដែលបានព្រមព្រៀងដោយប្រទេសជាសមាជិកនៃមហាអនុតំបន់ទន្លេមេគង្គ។ អត្ថបទទាំងស្រុងស្តីពីអនុស្សរណៈយោគយល់ មាននៅលើគេហទំព័រ www.greater-mekong.org/ttf។
- អនុស្សរណៈយោគយល់ (MoU) នេះអនុញ្ញាតឱ្យប្រទេសជាសមាជិកនីមួយៗអាចផ្តល់ជូននូវលិខិតអនុញ្ញាត (Permits) និងឯកសារអនុញ្ញាតិចូលបណ្តោះអាសន្ន (TADs) ដឹកជញ្ជូនផ្លូវថ្នល់សម្រាប់យានយន្តដឹកទំនិញ និង អ្នកដំណើរ ក្នុងមហាអនុតំបន់ទន្លេមេគង្គ រហូតដល់ចំនួន ៥០០ច្បាប់ ដល់ប្រតិបត្តិករដឹកជញ្ជូនរបស់ខ្លួន ដែលបានចុះបញ្ជីការ មានម្ចាស់កម្មសិទ្ធិ និង/ឬ ធ្វើប្រតិបត្តិការនៅក្នុងប្រទេសនោះ។
- យានយន្តទាំងឡាយអាចចរាចរនៅលើដងផ្លូវនិងឆ្លងកាត់ច្រកព្រំដែនណាមួយក៏បានដែលបានចុះបញ្ជីក្នុងពិធីការ CBTA 1 ដែលដែនវិសាលភាពនេះត្រូវបានពង្រីកនៅក្នុងឆ្នាំ២០២៣។ ចំពោះប្រទេសឡាវ ចរាចរណ៍ចូល និងចេញពីប្រទេសនេះ នឹងត្រូវបានដាក់កម្រិតកំណត់នៅតាមច្រកព្រំដែន បូតេន ហួយសាយ ដានសាវ៉ាញ និងសាវ៉ាន់ណាខេត ស្ថិតតាមបណ្តោយផ្លូវជាតិលេខ ៣ ៩ និង១៣។ ប្រទេសមីយ៉ាន់ម៉ា អាចនឹងចូលរួម «ដំណាក់កាលប្រមូលផលជំហានដំបូង (Early Harvest)» នៅត្រឹមឆ្នាំ២០២៧។ សូមចូលទៅគេហទំព័រ www.greatermekong.org/ttf ដើម្បីទទួលបានព័ត៌មានថ្មីៗស្តីពីបញ្ហានេះ។
- យានយន្តទាំងឡាយ ត្រូវភ្ជាប់មកជាមួយនូវលិខិតអនុញ្ញាត (Permits) និងឯកសារអនុញ្ញាតិចូលបណ្តោះអាសន្ន (TADs) ច្បាប់ដើមដែលផ្តល់ជូនដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសកំណើត (ពោលគឺប្រទេសដែលយានយន្តនោះត្រូវបានចុះបញ្ជីការ) ហើយអាចស្ថិតនៅក្នុងប្រទេសជាសមាជិកនៃមហាអនុតំបន់ទន្លេមេគង្គណាមួយ រហូតដល់រយៈពេល ៣០ថ្ងៃ នៅរាល់ការធ្វើដំណើរនីមួយៗ។
- ឯកសារអនុញ្ញាតិចូលបណ្តោះអាសន្ន (TAD) អាចត្រូវបានចាត់ទុកថាជា «លិខិតឆ្លងដែន» សម្រាប់យានយន្ត ហើយដែលត្រូវបោះត្រាទទួលស្គាល់ដោយនាយកដ្ឋានគយនៃប្រទេសជាម្ចាស់ផ្ទះនីមួយៗ (ពោលគឺ ប្រទេសជាសមាជិកនៃមហាអនុតំបន់ទន្លេមេគង្គផ្សេងទៀត) នៅរាល់ពេលឆ្លងកាត់ចូល និងចេញ ដើម្បីធានាបានថា រយៈពេលកំណត់ ៣០ថ្ងៃ ត្រូវបានត្រួតពិនិត្យ។
- ពុំមានការកំណត់ទៅលើចំនួនធ្វើដំណើរឆ្លងកាត់ព្រំដែនដែលទទួលបានការអនុញ្ញាតឡើយ។
- គំរូលិខិតអនុញ្ញាត (Permits) និងឯកសារអនុញ្ញាតិចូលបណ្តោះអាសន្ន (TADs) មាននៅលើគេហទំព័រ www.greatermekong.org/ttf ។








- ការផ្តល់ CBTA ជូនដល់ការដឹកជញ្ជូនទំនិញឆ្លងកាត់ (ដែលព្យួរកាតព្វកិច្ចបង់ពន្ធគយ) មិនត្រូវបានរាប់បញ្ចូលនៅក្នុង «ដំណាក់កាលប្រមូលផលដំហានដំបូង (Early Harvest)» ឡើយ។ នេះមានន័យថា បើទោះបីជាយានយន្តដែលទទួលបានការអនុញ្ញាត អាចឆ្លងកាត់ព្រំដែនបានក៏ពិតមែន ប៉ុន្តែប្រសិនបើមិនបានបង់ពន្ធ និងមិនតម្រូវឱ្យមានចំណងពន្ធគយ ឬការធានា នោះទំនិញដែលបានឆ្លងកាត់ត្រូវតែអនុវត្តតាមនីតិវិធីគយជាតិជាដាច់ខាត (ពោលគឺដូចនឹងការនាំចេញ/នាំចូលធម្មតា ដែលត្រូវមានការទូទាត់ពន្ធគយ គុណវិបត្តិកាតព្វកិច្ច ឬការព្យួរកាតព្វកិច្ចដោយប្រើប្រាស់របបឆ្លងកាត់ជាតិឬប្រព័ន្ធផ្សេងទៀតដែលបានព្រមព្រៀងទ្វេភាគីឬពហុភាគីរវាងប្រទេសទាំងឡាយដែលចូលរួមអនុវត្ត)។

## តើប្រតិបត្តិករដឹកជញ្ជូនអន្តរជាតិ អាចទទួលបាននូវលិខិតអនុញ្ញាត (Permits) និងឯកសារអនុញ្ញាតចូលបណ្តោះអាសន្ន (TADs) សម្រាប់ការដឹកជញ្ជូនតាមផ្លូវថ្នល់នៅតាមបណ្តាប្រទេសជាសមាជិកមហាអនុតំបន់ទន្លេមេគង្គ បានដោយរបៀបណា?

- នៅបណ្តាប្រទេសជាសមាជិកមហាអនុតំបន់ទន្លេមេគង្គមួយចំនួន អាជ្ញាធរដែលទទួលបន្ទុកផ្តល់ជូនលិខិតអនុញ្ញាត (Permits) និងឯកសារអនុញ្ញាតិចូលបណ្តោះអាសន្ន (TADs) គឺជាស្ថាប័នដូចៗគ្នា។ នៅបណ្តាប្រទេសមួយចំនួនផ្សេងទៀត អាជ្ញាធរទទួលបន្ទុកគឺជាស្ថាប័នផ្សេងគ្នា។
- នៅប្រទេសកម្ពុជា លិខិតអនុញ្ញាត (Permits) និងឯកសារអនុញ្ញាតិចូលបណ្តោះអាសន្ន (TADs) សម្រាប់ការដឹកជញ្ជូនតាមផ្លូវថ្នល់នៅតាមបណ្តាប្រទេសជាសមាជិកមហាអនុតំបន់ទន្លេមេគង្គអាចទទួលបានពី៖

**ក្រសួងសាធារណការ និងដឹកជញ្ជូន**
**លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្របសម្រួលដឹកជញ្ជូនឆ្លងកាត់ព្រំដែន**
**ជាន់ទី២ អគារ ក ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ ២**
**ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា**
**អ៊ីម៉ែល**: nttcc_kh@yahoo.com • **ទូរស័ព្ទ**: +855 77 881800

- ដើម្បីទទួលបានលិខិតអនុញ្ញាត (Permits) និងឯកសារអនុញ្ញាតិចូលបណ្តោះអាសន្ន (TADs) ប្រតិបត្តិករយានយន្ត ត្រូវបំពេញតាមលក្ខខន្តិកៈ ដូចមានចែងនៅក្នុងមាត្រា២ មាត្រា៣ មាត្រា៤ មាត្រា៥ និងមាត្រា៦ នៃឧបសម្ព័ន្ធ ៩ នៃ CBTA ពោលគឺ ប្រតិបត្តិករ ត្រូវតែ៖

ក) ជាប្រតិបត្តិករដឹកជញ្ជូនឆ្លងកាត់ព្រំដែនដែលបានចុះបញ្ជី និងទទួលបានលិខិតអនុញ្ញាត (Permits) និងឯកសារអនុញ្ញាតិចូលបណ្តោះអាសន្ន (TADs) នៅក្នុងប្រទេសកំណើតហើយយ៉ាងហោចណាស់មានភាគហ៊ុន៥១%និងដឹកនាំដោយបុគ្គលមានសញ្ជាតិក្នុងប្រទេសនោះ

ខ) ពុំមានជាប់ទោស ឬទណ្ឌកម្មពីប្រទេសកំណើត ហើយត្រូវមានកំណត់ត្រាផ្លូវច្បាប់ស្អាតស្អំ និងមិនមានជាប់ពាក់ព័ន្ធភាពក្ស័យធនបច្ចុប្បន្ន និង/ឬ មិនត្រូវបានដោះស្រាយ

គ) មានសមត្ថកិច្ចធ្វើប្រតិបត្តិការប្រកបដោយវិជ្ជាជីវៈ (ពោលគឺ គោរពតាមច្បាប់បញ្ញត្តិ ការគ្រប់គ្រងប្រតិបត្តិ បញ្ហាសុវត្ថិភាពតាមផ្លូវថ្នល់ និងលក្ខណៈបច្ចេកទេសដែលជាប់ទាក់ទងនឹងអាជីវកម្មដឹកជញ្ជូនតាមផ្លូវថ្នល់នៅតាមបណ្តាប្រទេសដែលគ្រោងនឹងឆ្លងកាត់)

ឃ) មានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ និងមានធានារ៉ាប់រងផ្នែកហិរញ្ញវត្ថុ ទៅលើទំនួលខុសត្រូវកិច្ចសន្យា និង/ឬ ប្រតិបត្តិការ



National Transport Facilitation Committee, Cambodia

**GMS Road Transport Permit**[1]

This document is issued in accordance with Protocol 3 and Article 23 of the Agreement between and among the Governments of the Kingdom of Cambodia, the People's Republic of China, the Lao People's Democratic Republic, the Union of Myanmar, the Kingdom of Thailand, and the Socialist Republic of Viet Nam for the Facilitation of Cross-Border Transport of Goods and People

**Permit No.**

| Country code | Permit number | Barcode |
|---|---|---|
| | | |

**Type of Permit/Transport Operation:**[2] ☐ Scheduled passenger ☐ Non-scheduled passenger ☐ Cargo

**1. Issuing Authority:**
1.1 Name: National Transit Transport Coordination Committee (NTTCC)
1.2 Address: Cnr. Norodom Blvd. & St. 106, Phnom Penh, Cambodia
1.3 Contact Data:[3] HEAD of NTTCC: Tel: +855 12 959599 (Secretary of State) • SECRETARIAT: Tel: +855 77 881800 • Email: cambodia_nttcc@yahoo.com

**2. Beneficiary of the Permit:**[4]
2.1 Name:
2.2 Address:
2.3 Contact Data:
2.4 Road Transport Operator's National License Number:[5]

**3. Particulars for Scheduled Passenger Transport Operations Only:**
3.1 Itinerary:
3.2 Frequency of operations for the beneficiary:
3.3 Maximum Capacity (number of seats/persons):
3.4 Other Restrictions:[6]

**4. Period of Validity:**[7] from ______ until ______

**5. Allocated Vehicle Registration Number:**[8]

| | Prime mover/Truck/Bus | Semi-trailer | | Prime mover/Truck/Bus | Semi-trailer |
|---|---|---|---|---|---|
| 1 | | | 5 | | |
| 2 | | | 6 | | |
| 3 | | | 7 | | |
| 4 | | | 8 | | |

Place and Date of Issuance ______ Authentication (Seal/Stamp, Signature): ______








## តើបញ្ហាអនុលោមភាពអ្វីផ្សេងទៀត ដែលប្រតិបត្តិករត្រូវយល់ដឹង?




- ដូចមានចែងនៅក្នុងអត្ថបទគោលនៃ CBTA និងអនុស្សរណៈយោគយល់ «ដំណាក់កាលប្រមូលផលជំហានដំបូង (Early Harvest)» ប្រតិបត្តិករទាំងឡាយ ត្រូវប្រកាន់ខ្ជាប់តាមលក្ខខណ្ឌគោល CBTA ដើម្បីទទួលបានលិខិតអនុញ្ញាតយានយន្តផ្លូវគោក ពោលគឺមាត្រា១១ដល់មាត្រា១៨នៃអត្ថបទគោល CBTA ដែលត្រូវអនុលោមតាមៈ ក) ការចុះបញ្ជីយានយន្ត; ខ) លក្ខខណ្ឌបច្ចេកទេសយានយន្ត; គ) វិញ្ញាបនបត្រត្រួតពិនិត្យបច្ចេកទេសយានយន្តដែលមានសុពលភាព; ឃ) ធានារ៉ាប់រងយានយន្តដោយភាគីទីបីជាកំហិត; និង ង) លិខិតអនុញ្ញាតបើកបរ។
- ប្រតិបត្តិករទាំងឡាយ គួរកត់ចំណាំថា យានយន្ត ត្រូវតែបំពេញតាមបទដ្ឋានសុវត្ថិភាពបរិក្ខារនិងការបំភាយឧស្ម័ននៅក្នុងប្រទេសនិងអនុលោមតាមបទដ្ឋានបច្ចេកទេសនៃទម្ងន់យានយន្តបន្ទុកអ័ក្សនិងវិមាត្រនៃប្រទេសជាម្ចាស់។ព័ត៌មានស្ដីពីកត្តាខាងក្រោយ មាននៅលើគេហទំព័រ www.greatermekong.org/ttf ។
- ប្រតិបត្តិករ ត្រូវយល់ដឹង និងគោរពតាមកម្រិតទម្ងន់ និងលក្ខខណ្ឌសុវត្ថិភាពផ្លូវគោក នៃប្រទេសម្ចាស់ផ្ទះ ដែលពួកគេតែងធ្វើប្រតិបត្តិការ។ កាលវិភាគ និងបន្ទុកទម្ងន់ គួររៀបចំទុកជាមុនស្របតាមលក្ខខណ្ឌទាំងនេះ។ ការខកខានមិនគោរពតាមច្បាប់ អាចនឹងត្រូវប្រឈមមុខនឹងការលុបចោលនូវលិខិតអនុញ្ញាត និងការដកឈ្មោះប្រតិបត្តិករចេញពី CBTA ។
- ប្រតិបត្តិករ ត្រូវតាមដានចំនួនកំណត់ ៣០ថ្ងៃ ដែលបានអនុញ្ញាត ក្នុងការធ្វើដំណើរមួយលើកៗឆ្លងកាត់ប្រទេសម្ចាស់ផ្ទះ។ចំនួនថ្ងៃដែលបានកំណត់នេះអនុវត្តដោយស្មើភាពចំពោះកុងតឺនឺដឹកទំនិញ។ ការខកខានមិនបានតាមដានអាចប្រឈមមុខនឹងការផាកពិន័យនិងទណ្ឌកម្មផ្សេងទៀតរួមមានការលុបចោលនូវលិខិតអនុញ្ញាត និងនិងការដកឈ្មោះប្រតិបត្តិករចេញពី CBTA ដូចមានចែងនៅក្នុងអនុស្សរណៈយោគយល់ «ដំណាក់កាលប្រមូលផលជំហានដំបូង (Early Harvest)» ។
- ការដឹកជញ្ជូន (រួមមាន ការដឹកជញ្ជូនទំនិញ ឬអ្នកដំណើររវាងគោលដៅចំនួនពីរ ស្ថិតនៅក្នុងប្រទេសម្ចាស់ផ្ទះ ដោយប្រតិបត្តិករដឹកជញ្ជូនមកពីបណ្ដាប្រទេសជាសមាជិកមហាអនុតំបន់ទន្លេមេគង្គផ្សេងទៀត) មិនត្រូវទទួលបានការអនុញ្ញាតឡើយ។ ប្រតិបត្តិករដែលជាប់ពាក់ព័ន្ធនឹងការដឹកជញ្ជូនមិនទទួលបានការអនុញ្ញាត ត្រូវប្រឈមមុខនឹងការលុបចោលនូវលិខិតអនុញ្ញាត និងការដកឈ្មោះប្រតិបត្តិករចេញពី CBTA ។

## តើមានអ្វីខ្លះ នឹងកើតឡើង?

- កិច្ចព្រមព្រៀងសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន (CBTA) «ដំណាក់កាលប្រមូលផលជំហានដំបូង (EARLY HARVEST)» នឹងចាប់អនុវត្ត ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៦ (អាចត្រូវបានពន្យារពេល)។
- ប្រទេសជាសមាជិកមហាអនុតំបន់ទន្លេមេគង្គទាំងប្រាំ (លើកលែងមីយ៉ាន់ម៉ា) ត្រូវបានរំពឹងថាចាប់ផ្ដើមផ្ដល់លិខិតអនុញ្ញាត (Permits) និងឯកសារអនុញ្ញាតិចូលបណ្ដោះអាសន្ន (TADs) ដែលមានការទទួលស្គាល់រវាងគ្នា បានភ្លាមៗរហូតដល់ចំនួនកំណត់ ៥០០ច្បាប់។
- ព័ត៌មាន និងបច្ចុប្បន្នភាពផ្សេងទៀត នឹងមានផ្ដល់ជូននៅលើគេហទំព័រ www.greatermekong.org/ttf នៅក្នុងផ្នែក ការអនុវត្ត «ដំណាក់កាលប្រមូលផលជំហានដំបូង (Early Harvest)» ។
- ប្រទេសមីយ៉ាន់ម៉ាបានព្រមព្រៀងលើចំនួនកូតាយានយន្តឆ្លងកាត់ទ្វេភាគី (២០០យានយន្ត) ជាមួយនឹងប្រទេសថៃហើយកំពុងចរចារកិច្ចព្រមព្រៀងស្រដៀងគ្នា ជាមួយនឹងប្រទេសឡាវ និងសាធារណរដ្ឋប្រជាមានិតចិន នៅមុនពេលចូលរួមអនុវត្ត «ដំណាក់កាលប្រមូលផលជំហានដំបូង (Early Harvest)» ឬការកែសម្រួល CBTA នៅត្រឹមឆ្នាំ២០២៧ ។










ខែកុម្ភៈ ឆ្នាំ២០២៤

គាំទ្រក្រោមគម្រោងជំនួយបច្ចេកទេសលេខ TA 6579-REG ៖ ការអនុវត្តកិច្ចព្រមព្រៀងសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន
«ដំណាក់កាលប្រមូលផលជំហានដំបូង» ក្នុងមហាអនុតំបន់ទន្លេមេគង្គ
តាមរយៈសហហិរញ្ញប្បទាន ដោយ រដ្ឋាភិបាលនៃចក្រភពអង់គ្លេស

សម្រាប់ព័ត៌មានបន្ថែមស្តីពីការគាំទ្ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ទៅលើការអនុវត្ត «ដំណាក់កាលប្រមូលផលជំហានដំបូង (EH)»
សូមទំនាក់ទំនង Mohammad Ehteshamul Hoque ជំនាញការពាណិជ្ជកម្ម តាមរយៈ mehoque@adb.org